# សេចក្តីថ្លែងការណ៍រួម

## សង្គមស៊ីវិលព្រួយបារម្ភ និងផ្តល់អនុសាសន៍ទៅលើសេចក្តីព្រាងច្បាប់ស្តីពីអស្សាមិករណ៍

សង្គមស៊ីវិល ដែលរួមមាន គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC), វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum), ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF), អង្គការស្តារកម្ពុជា (Star Kampuchea), គណៈកម្មាធិការ ដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌ នៅកម្ពុជា (COMFREL), និង អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និង អន្តរជាតិមួយចំនួន ព្រមទាំងសហគមន៍ ដែលធ្វើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា សូមសំដែងនូវក្តីបារម្ភជុំវិញ **សេចក្តីព្រាងច្បាប់ស្តីពីអស្សាមិករណ៍**[១] ដែលនឹងត្រូវបានសភាជាតិកម្ពុជា លើកយកមកជជែកពិភាក្សានៅក្នុងសម័យប្រជុំរបស់ខ្លួននៅពេលខាងមុខនេះ ។

សង្គមស៊ីវិលខាងលើ កត់សំគាល់ថា សេចក្តីព្រាងច្បាប់នេះមានចំណុចព្រួយបារម្ភជាច្រើន និងថា ប្រសិនបើ សេចក្តីព្រាងច្បាប់នេះត្រូវបានសភាជាតិ អនុម័តស្របទៅតាមខ្លឹមសារដើមទាំងស្រុងនោះ នឹងធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងទៅលើផលប្រយោជន៍របស់ម្ចាស់កម្មសិទ្ធិ ម្ចាស់សិទ្ធិ ជាពិសេសប្រជាពលរដ្ឋក្រីក្រដែលងាយរងគ្រោះ ដោយសារតែច្បាប់នេះអនុញ្ញាតឱ្យអាជ្ញាធរសាធារណៈប្រើប្រាស់សិទ្ធិក្នុងការបណ្តេញចេញ ការជំលៀសចេញ និង ការរុះរើចេញនូវអចលនវត្ថុរបស់បុគ្គលឯកជន ហើយពួកគេក៏អាចប្រឈមមុខនឹងការបាត់បង់ទាំងស្រុង ឬការមិនទទួលបានសំណងសមរម្យ និង យុត្តិធម៌ សំរាប់ជួសជុលការខូចខាតទាំងនោះផងដែរ ។

ដើម្បីឆ្លើយតបចំពោះការព្រួយបារម្ភ និងក្តីកង្វល់ ក៏ដូចជា ដើម្បីធ្វើប្រសើរឡើងនូវខ្លឹមសារ និងស្មារតីនៃច្បាប់ស្តីពីអស្សាមិករណ៍នេះ សង្គមស៊ីវិល ព្រមទាំងសហគមន៍នានា ដែលបានតាមដានយ៉ាងយកចិត្តទុកទៅលើសេចក្តីព្រាងច្បាប់នេះ សូមស្នើសុំយ៉ាងទទូចដល់ សមាជិក សមាជិការដ្ឋសភា មេត្តាជជែកពិភាក្សាខ្លឹមសារ និង គោលបំណងនៃច្បាប់នេះឱ្យបានស៊ីជំរៅ ដើម្បីធានាឱ្យមានការការពារ និងការគោរពសិទ្ធិស្របច្បាប់ និងសិទ្ធិមនុស្ស ជាពិសេស ដើម្បីជួយធ្វើឱ្យមានអប្បរមាភាពនូវផលប៉ះពាល់ពីការធ្វើអស្សាមិករណ៍ ។

ដូចនេះ សង្គមស៊ីវិល ព្រមទាំងសហគមន៍នានា សូមស្នើសុំឱ្យរដ្ឋសភាមេត្តាពិចារណា និងដាក់បញ្ចូលនូវអនុសាសន៍ ទាំង ១៤ ចំណុច ទៅក្នុងការជជែកពិភាក្សា និងដាក់បញ្ចូលនៅក្នុងខ្លឹមសារច្បាប់ ដែលរួមមានដូចខាងក្រោម :

[១] សេចក្តីព្រាងច្បាប់ដែលអង្គការសង្គមស៊ីវិលបានពិភាក្សា គឺសេចក្តីព្រាងចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ។ សេចក្តីព្រាងនេះត្រូវបានសង្គមស៊ីវិលដាក់ឱ្យមានការពិគ្រោះពិភាក្សាកាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩ នៅសណ្ឋាគារអ៊ីមភើរៀល ដោយបង្កើតបាននូវអនុសាសន៍រួម ។

១. ច្បាប់អស្សាមិករណ៍គួរគ្របដណ្ដប់ទាំងម្ចាស់កម្មសិទ្ធិ និងម្ចាស់សិទ្ធិ ព្រោះបច្ចុប្បន្នអាត្រាប្រជាពលរដ្ឋ ដែលមានប័ណ្ណកម្មសិទ្ធិលើដីធ្លី និងផ្ទះសំបែងនៅមានកម្រិត (ច្បាប់ភូមិបាល ក៏បានការពារសិទ្ធិអ្នកកាន់កាប់ស្របច្បាប់) ។ ចំពោះការដកហូតអចលនវត្ថុប្រជាពលរដ្ឋ ត្រូវអនុវត្តតែក្នុងគោលបំណងបម្រើផលប្រយោជន៍ជាតិ និងផលប្រយោជន៍សាធារណៈប៉ុណ្ណោះ (មាត្រា២) ។

២. រាល់អនុស្សារណៈនិងកិច្ចព្រមព្រៀងស្ដីពីការគាំពារវិនិយោគរវាងរដ្ឋាភិបាល និងប្រទេសជាដៃគូ ត្រូវស្ថិតនៅក្រោមវិសាលភាពច្បាប់នៃព្រះរាជាណាចក្រកម្ពុជា (មាត្រា៣) ។

៣. គួរកំណត់ឱ្យច្បាស់អំពីពាក្យ *"ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ"* ព្រោះមានន័យទូលំទូលាយ ដែលអាចឱ្យមានការបកស្រាយបានច្រើនយ៉ាង និងគួរបញ្ចូលការការពារផលប្រយោជន៍ជនជាតិដើមភាគតិច ដែលដីសមូហភាពរបស់ជនជាតិដើមភាគតិចគួរតំរូវឱ្យមានការចុះបញ្ជីកម្មសិទ្ធិជាមុន មុនពេលធ្វើអស្សាមិករណ៍ ព្រោះជនជាតិដើមភាគតិចជាជនងាយរងគ្រោះ និង អាចជាកម្មវត្ថុនៃការកេងបន្លំ (មាត្រា៤) ។

៤. ការដកហូតអចលនវត្ថុរបស់ប្រជាពលរដ្ឋគួរធ្វើអប្បរមានីយកម្ម ដែលចំណុចនេះមានចែងនៅក្នុងសេចក្ដីព្រាងចាស់ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ តែត្រូវបានដកចេញនៅសេចក្ដីព្រាងថ្មីចុះថ្ងៃ ទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៩ អាស្រ័យហេតុនេះ ស្នើសុំបន្ថែមមាត្រានេះឡើងវិញ (មាត្រា៧ចាស់) ។

៥. ក្នុងករណីគំរោងអស្សាមិករណ៍ពុំមានដំណើរការក្នុងរយៈពេល ២ឆ្នាំ ដីដែលបានដកហូត ត្រូវប្រគល់ឱ្យប្រជាពលរដ្ឋវិញ (កុំទុកឱ្យដីទំនេរចោល) (មាត្រា៩) ។

៦. ត្រូវធានាឱ្យបានថាប្រជាពលរដ្ឋត្រូវមានទីជម្រក និងទីលំនៅថ្មីសមរម្យ ទោះក្នុងករណីបន្ទាន់បង្ខំយ៉ាងណាក៏ដោយ (មាត្រា១០) ។

៧. រាល់ការងារអស្សាមិករណ៍ ត្រូវជាបន្ទុកនៃការទទួលខុសត្រូវរបស់គណៈកម្មាធិការអស្សាមិករណ៍ និងអនុគណៈកម្មាធិការអស្សាមិករណ៍តែប៉ុណ្ណោះ។ រាល់អនុក្រឹត្យដែលនឹងបង្កើតឡើងតាមច្បាប់នេះ ត្រូវប្រកាស និងផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានពិគ្រោះយោបល់ (មាត្រា១២) ។

៨. គួរកំណត់អំពី តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាធិការអស្សាមិករណ៍ និងអនុគណៈកម្មាធិការអស្សាមិករណ៍ ដើម្បីទទួលបន្ទុកលើរាល់ការងារអស្សាមិករណ៍ព្រមទាំងទំនាក់ទំនងរបស់គណៈកម្មាធិការទាំងពីរ (មាត្រា១៣) ។

៩. ត្រូវបញ្ចូល *"សហគមន៍ដែលរងគ្រោះផ្ទាល់"* ទៅក្នុងការពិគ្រោះយោបល់សាធារណៈ និងនៅក្នុង *រយៈពេលសមស្រប* (មាត្រា ១៦) ។

១០. ត្រូវផ្ដល់សិទ្ធិដល់ម្ចាស់អចលនវត្ថុ និងម្ចាស់សិទ្ធិ ក្នុងការប្ដឹងតវ៉ាអំពីសំណើស្ដីពីគំរោងធ្វើអស្សាមិករណ៍ និង រយៈពេលសមរម្យ (មាត្រា១៦) ។

១១. ត្រូវចែងថា ការដកហូតអចលនវត្ថុរបស់ប្រជាពលរដ្ឋមិនអាចប្រព្រឹត្តទៅបានទេ ប្រសិនបើការដោះស្រាយមិនទាន់បញ្ចប់ ( មាត្រា១៩ ) ។

១២. សំណងសមរម្យ និងយុត្តិធម៌ គួររាប់បញ្ចូលទាំងតម្លៃទីផ្សារបច្ចុប្បន្ន តម្លៃជីវភាព និងតម្លៃវប្បធម៌ប្រពៃណី ជាពិសេសករណីទាក់ទិននឹងជនជាតិភាគតិច។ គួរត្រូវសិក្សាឱ្យបានច្បាស់ពីតំលៃទីផ្សារ និងធ្វើការផ្សព្វផ្សាយជាសាធារណៈ ( មាត្រា២២ ) ។

១៣. គួរផ្ដល់ពេលគ្រប់គ្រាន់ដល់ប្រជាពលរដ្ឋរងផលប៉ះពាល់យ៉ាងតិចរយៈពេល៣ (បី)ខែ ដើម្បីអាចស្វែងរកទីតាំងថ្មីបានដោយងាយស្រួល ( មាត្រា៣១ ) ។

១៤. គួរកម្រិតទោសទណ្ឌឱ្យបានធ្ងន់ធ្ងរចំពោះមន្ត្រីមានសមត្ថកិច្ច និង អ្នកសមគំនិតដែលធ្វើអស្សាមិករណ៍មិនយកបម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ ព្រមទាំងមិនគោរពទៅតាមនីតិវិធីអស្សាមិករណ៍ឱ្យបានត្រឹមត្រូវ ដូចជា ទណ្ឌកម្មខាងរដ្ឋបាល ការផ្តន្ទាទោសដាក់ពន្ធនាគារ និងការពិន័យ ( មាត្រា៣៥ ) ។

*ភ្នំពេញ ថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០០៩*

***សំរាប់ព័ត៌មានលំអិត សូមទំនាក់ទំនង:***


| | | |
|---|---|---|
| លោក ហង្ស ឆាយា | ប្រធានសំរបសំរួល CHRAC និងជានាយក KID | លេខ: ០១២ ៨៦៥ ៩១០ |
| លោក ធន សារាយ | ប្រធានសមាគមអាដហុក ADHOC | លេខ: ០១៦ ៨៨០ ៥០៩ |
| លោក សុក សំអឿន | នាយកប្រតិបត្តិ CDP | លេខ: ០១២ ៩០១ ១៩៩ |
| លោក ឈិត សំអាត | នាយកប្រតិបត្តិ NGO Forum | លេខ: ០១២ ៩២៨ ៥៨៥ |
| លោក យ៉េង វីរៈ | នាយកប្រតិបត្តិ CLEC | លេខ: ០១២ ៨០១ ២៣៥ |
| លោក អ៊ូ វីរៈ | ប្រធាន CCHR | លេខ: ០១២ ៤០៤ ០៥១ |
| លោក សៀ ភិរម្យ | នាយកលេខាធិការដ្ឋាន HRTF | លេខ: ០១២ ៨៥២ ៣២៥ |
| លោកស្រី ជេត ចរិយា | នាយិកាប្រតិបត្តិអង្គការស្ពានកម្ពុជា Star Kampuchea | លេខ: ០១២ ៨០២ ៤៦០ |
| លោក គល់ បញ្ញា | នាយកប្រតិបត្តិ COMFREL | លេខ: ០១២ ៩៤២ ០១៧ |
| លោក ធាន សារុំ | ប្រធានគ្រប់គ្រងប្រតិបត្តិការ WV-Cambodia | លេខ: ០១២ ៦៥៦ ១៨១ |
| លោក David Pred | នាយកប្រចាំប្រទេសកម្ពុជានៃ BABSEA | លេខ: ០៩២ ២៨៥ ៩៥៤ |